# ជំពូក ១

## សេចក្តីផ្តើម

## INTRODUCTION

Draft

Draft

# ជំពូកទី ១

## សេចក្តីផ្តើម (Introduction)

### ១.១ លក្ខណៈទូទៅ

សំដៅរួមចំណែកដល់កិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងព្រៃឈើ ការរក្សាគុណភាពទឹក ដី ខ្យល់ និងសុវត្ថិភាពប្រព័ន្ធអេកូឡូស៊ីប្រកបដោយប្រសិទ្ធភាព និងតាមទិសដៅរបស់អង្គការសហប្រជាជាតិស្តីពី "អនាគតដែលយើងចង់បាន" ដែលរាជរដ្ឋាភិបាលបាន នឹងកំពុងអនុវត្តរាល់ថ្ងៃ លើវិស័យជលផល និងវិស័យព្រៃឈើ ការប្រើប្រាស់ថាមពល និងទឹកដោយសន្សំសំចៃ ការប្រើប្រាស់ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជន និងការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ដើម្បីថែរក្សាធនធានធម្មជាតិជូនអ្នកជំនាន់ក្រោយ ដោយដើរទន្ទឹមនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

គោលការណ៍អភិវឌ្ឍន៍បៃតង គឺធ្វើឱ្យមានតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ជាមួយនឹងបរិស្ថានសង្គម និងវប្បធម៌ ដើម្បីសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងបរិយាកាសនៃស្ថានភាពបច្ចុប្បន្ននេះ មុខសញ្ញាវិនិយោគគ្រប់ប្រភេទសុទ្ធតែមានសារៈសំខាន់សម្រាប់កម្ពុជាទាំងអស់ ទាំងការវិនិយោគផលិតទំនិញនាំចេញ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគលើវិស័យឧស្សាហកម្ម កសិកម្ម កសិ-ឧស្សាហកម្ម ការស្វែងរក ប្រភពទាក់ទាញទេសចរណ៍ សេវាកម្ម និងការផលិតថាមពលអគ្គិសនីដោយប្រើចរន្តទឹក គឺវារីអគ្គិសនី ដែលជាសក្តានុពល ដ៏សំខាន់នៃការរីកចំរើន នៃសេដ្ឋកិច្ចរបស់កម្ពុជា ។

ពិតមែនតែគ្រប់វិស័យសុទ្ធតែមានសារៈសំខាន់ដូចៗគ្នា សម្រាប់បំរើការអភិវឌ្ឍ ប៉ុន្តែវារីអគ្គិសនីជាវិស័យអាទិភាពមួយ ដែលមានលក្ខណៈសមស្រប និងចាំបាច់បំផុតចំពោះស្ថានភាពបច្ចុប្បន្នប្រេងឥន្ធនៈឡើងថ្លៃ ហើយមិនបំពុលខ្យល់ (ដោយ $CO_2$, $NO_X$, $SO_x$...etc ដែលធ្វើឱ្យកំដៅបរិយាកាសផ្ទះកញ្ចក់ផែនដីឡើងទៀតផង)។ ដោយហេតុថា ប្រទេសកម្ពុជាស្ថិតក្នុងតំបន់ត្រូពិច ដែលមានភ្លៀង ធ្លាក់រយៈពេលប្រាំមួយខែក្នុងមួយឆ្នាំរួមផ្សំ នឹងសណ្ឋានដីសំបូរដោយជួរភ្នំ និងជ្រលងភ្នំនៅតាមបន្ទាត់ព្រំដែន និងតំបន់ឆ្នេរបង្គឱ្យ មានសក្តានុពលសម្រាប់អភិវឌ្ឍន៍វារីអគ្គិសនី ជាពិសេសគឺជួរភ្នំក្រវាញខេត្តពោធិ៍សាត់ និងតំបន់ខេត្តពោធិ៍សាត់ នេះតែម្តង ។

ក្នុងគោលដៅស្រូបយកផលប្រយោជន៍ដ៏សំបូរបែប ដែលជាអំណោយផលធម្មជាតិរបស់កម្ពុជា និងក្នុងគោលដៅចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យ ស្របតាមគោលនយោបាយ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល គឺ ទឹក(ទឹកស្អាតសម្រាប់បរិភោគ និងទឹកសម្រាប់កសិកម្ម) ផ្លូវ ភ្លើង(អគ្គិសនី) និងមនុស្ស។

ផ្អែកតាមគោលនយោបាយ ខាងលើ គម្រោងវារីអគ្គិសនីនៅប្រទេសកម្ពុជា ត្រូវបានធ្វើការវិនិយោគជាច្រើនកន្លែង ដោយឡែក គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ខេត្តពោធិ៍សាត់ ត្រូវបានចាប់អារម្មណ៍ពីក្រសួងរ៉ែ និងថាមពលផងដែរ។ គម្រោងវារីអគ្គិសនីនេះ បានធ្វើការសិក្សា ៣ ជំហ៊ានសំខាន់ៗ គឺ ១) ការសិក្សាបុរេសមិទ្ធលទ្ធភាព ដោយក្រុមហ៊ុន HEC ២) ការសិក្សាសមិទ្ធលទ្ធភាព ដោយក្រុមហ៊ុន HEC ការសិក្សាទាំងពីរនេះ វារីអគ្គិសនីនេះមានលទ្ធភាព បំពាក់ទួរប៊ីនកម្លាំង ៤០ MW ហើយដំណើរការផលិតអគ្គិសនី១ឆ្នាំពេញ។ ៣)ការធ្វើបច្ចុប្បន្នភាពសមិទ្ធលទ្ធភាព ដោយក្រុមហ៊ុន SINOHYDRO វារីអគ្គិសនីនេះមានលទ្ធភាពបំពាក់ទួរប៊ីនកម្លាំង៨០MWដែលអាចផលិតអគ្គិសនីបានប្រមាណ៣៦៧,១២GWh ក្នុងមួយឆ្នាំ។

យោងតាម លិខិតអនុញ្ញាតរបស់ក្រសួងរ៉ែ និងថាមពល ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ បានឱ្យក្រុមហ៊ុន KTC Cable Co.,Ltd (KTC) សិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះឡើង។ ក្រុមហ៊ុននេះ បានជ្រើសយកក្រុមហ៊ុន Hyundai Engineering Co., Ltd (HEC) ជាទីប្រឹក្សាបច្ចេកទេស ធ្វើការសិក្សា និងរៀបចំជារបាយការណ៍ សិក្សាបុរេសមិទ្ធិលទ្ធភាព នៃគម្រោងនេះឡើង នៅខែ កញ្ញា ឆ្នាំ ២០១០ គឺ ប្រើពេល ៦ខែ ។ របាយការណ៍នេះបានដាក់សុំអនុសាសន៍ពី ក្រសួងរ៉ែ និងថាមពលក្នុងខែដដែលនេះ។

Draft

យោងតាមសំណើរបស់ក្រុមហ៊ុន KTC ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ ឯ.ឧ អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល បានចុះហត្ថលេខា អនុញ្ញាតឱ្យក្រុមហ៊ុន KTC នេះ ដោយសហការជាមួយក្រុមហ៊ុន KHNP ធ្វើការសិក្សា សមិទ្ធិលទ្ធភាព រហូតដល់ខែវិច្ឆិកា ឆ្នាំ២០១២ ។ ក្រុមហ៊ុន KTC ក៏បានឱ្យក្រុមហ៊ុន Hyundai Engineering ធ្វើការសិក្សាលទ្ធភាពបន្ថែមទៀតផងដែរ។ ជាចុងក្រោយ នៅខែមិនា ឆ្នាំ២០១២ ក្រុមហ៊ុន KTC បានសរសេរលិខិត ស្នើសុំពន្យារពេលសម្រាប់ការសិក្សានេះទៅក្រសួង។ ឯ.ឧ ស៊ុយ សែម រដ្ឋមន្ត្រី នៃក្រសួង រ៉ែ និងថាមពល បានចុះហត្ថលេខា អនុញ្ញាត ឱ្យពន្យារពេល នៃការសិក្សាសមិទ្ធិលទ្ធភាពនេះ ដល់ខែធ្នូ ឆ្នាំ ២០១២ វិញ។ ***សម្គាល់:*** *ក្រុមហ៊ុន Hyundai Engineering នេះក៏ជាអ្នកទទួលខុសត្រូវរៀបចំរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញនេះផងដែរ។* យោងតាមរបាយការណ៍នេះ វារីអគ្គិសនីស្ទឹងពោធិ៍សាត់១ អាចដំណើរការបាន ៣៦៥ថ្ងៃ/ឆ្នាំ ហើយអាចផលិតអគ្គិសនីបាន ២៨៥,៥៥ លាន kWh/ឆ្នាំ ដោយដំឡើងទួរប៊ីន ២ ដែលមានកម្លាំងសរុប ៤០ MW ។

យោងតាមការធ្វើបច្ចុប្បន្នភាពសមិទ្ធិលទ្ធភាពគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ មួយថ្មីទៀត ដែលសិក្សាដោយ Power China / SINOHYDRO របស់ប្រទេសចិន ដែលទើបបានបញ្ចប់ នៅខែកុម្ភៈ ឆ្នាំ២០១៧ គម្រោងនេះ ដំណើរការនៅរដូវប្រាំង ដោយយោងតាមតម្រូវការរបស់ EDC រយៈពេល៦ខែពេញ ដែលអាចផលិតអគ្គិសនីបាន ៣៦៧,១២ លាន kWh/ឆ្នាំ និងដំឡើងទួរប៊ីន ២ ហើយមានកម្លាំងសរុប ៨០MW វិញ។ គម្រោងនេះ គ្រោង នឹងវិនិយោគ ជាប្រវត្តិសាស្ត្រ រួមគ្នារវាងក្រុមហ៊ុន KTC, ក្រុមហ៊ុន K WATER, ក្រុមហ៊ុន TURBEN Investment របស់ប្រទេសកូរ៉េ (ខាងត្បូង) និងក្រុមហ៊ុន SINOHYDRO របស់ប្រទេសចិន (KTC ជាក្រុមហ៊ុន តំណាងឱ្យម្ចាស់គម្រោងនៃក្រុមហ៊ុនទាំង៤នេះ ហើយក្នុងការពិពណ៌នាក្នុងរបាយការណ៍នេះគឺយកឈ្មោះKTCមកបរិយាយប៉ុណ្ណោះ ព្រោះ KTC ជាអ្នកទទួលបានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពលឱ្យសិក្សាគម្រោងនេះ)។ ***សម្គាល់:*** *វារីអគ្គិសនីភាគច្រើនក្នុងប្រទេសកម្ពុជា នៅរដូវប្រាំងផលិតអគ្គិសនី មិនបានតាមតម្រូវការរបស់ EDC ឡើយ។ គម្រោងនេះ មានលទ្ធភាពផលិតអគ្គិសនីបាននៅរដូវប្រាំង បាន២៨០,៥២ GWh*

ក្រុមហ៊ុន Hyundai Engineering Co., Ltd បានធ្វើកិច្ចព្រមព្រៀងជាមួយ នឹង SAWAC Consultants (Cambodia) Co., Ltd. ដើម្បីរៀបចំរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) នៃគម្រោងនេះ។ ឆ្លើយតបតាមតម្រូវការនេះ SAWAC បានចាត់ក្រុមអ្នកជំនាញ ដែលទាក់ទងនឹងផ្នែកបរិស្ថាន អនុបណ្ឌិតសំណង់ស៊ីវិល ផ្នែកសំណង់ជលគតិ (MSc of Hydraulic Engineering Construction), វិស្វករបរិស្ថាន (Environmental Engineer), អ្នកជំនាញផ្នែក សេដ្ឋកិច្ច-សង្គម (Socio-Economist), វិស្វករជលផល (Fishery Engineer), វិស្វករព្រៃឈើ (Forest Engineer), អ្នកជំនាញផ្នែកព័ត៌ មានភូមិសាស្ត្រ (GIS Specialist), ក្រុមអ្នកសម្ភាស និងកម្លាំងរក្សាសន្តិសុខបានចុះទៅធ្វើការសិក្សាផ្ទាល់ នៅក្នុងតំបន់គម្រោង ដូចជា តំបន់ហេដ្ឋារចនា ក្នុងតំបន់អាង និងតំបន់អាគារថាមពល ប្រមាណជាង ៩.៣៥៥ ហ.ត ដែលស្ថិតក្នុងការគ្រប់គ្រង រដ្ឋបាលរបស់ ភូមិ ស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ហើយធ្វើការវិភាគ និងរៀបចំរបាយការណ៍នេះ សម្រេចចាប់ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១២ ដល់ ៩ ខែវិច្ឆិកា ឆ្នាំ ២០១២ សរុបមាន រយៈពេល១០ខែ។ ដោយឡែករបាយការណ៍នេះ បានធ្វើបច្ចុប្បន្នភាពផ្នែកសេដ្ឋកិច្ច-សង្គម នៅខែ កញ្ញា ឆ្នាំ២០១៥ និងធ្វើម្តងទៀតខែ តុលា ដល់ខែ វិច្ឆកា ២០១៧ នេះផងដែរ។ ។

យោងតាម លិខិតលេខ ០១៩ ស.ជ.ណ ប.ស្ល ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ ២០១៧ របស់ក្រសួងបរិស្ថានជម្រាបជូនលោកប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន KTC CABLE Co., Ltd តម្រូវឱ្យក្រុមហ៊ុន ទីប្រឹក្សាក្នុងការសិក្សា កែសម្រួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ កម្លាំង ៨០ មេហ្គាវ៉ាត់វិញ។ យោងតាម របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងការធ្វើបច្ចុប្បន្នភាពសមិទ្ធិលទ្ធភាព នៃគម្រោងនេះ ផ្ទៃដីតម្រូវអភិវឌ្ឍគម្រោងមិនមានការប្រែប្រួលឡើយ គឺមានសរុបប្រមាណ ៩.៣៥៥ ហ.ត ដោយកម្រិតពស់នីវ៉ូ តម្ពល់ទឹកក្នុងអាងធម្មតាមាន ១៨០ម ដដែល។

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) នេះរៀបចំទៅតាមប្រកាសស្តីពី គោលការណ៍ណែនាំទូទៅ ក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លេខ ៣៧៦ ប្រក ប.ស្ល ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០០៩។ របាយការណ៍ ESIA នេះមាន ១០ ជំពូកគឺ (១)សេចក្តីផ្តើម, (២)វិធីសាស្ត្រនៃការសិក្សា, (៣)ក្របខ័ណ្ឌច្បាប់ ដែលពាក់ព័ន្ធ, (៤)ការពិពណ៌នាអំពីគម្រោង, (៥) បរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គម្រោង, (៦)ការ



Draft

ចូលរួម ពីសាធារណៈជន, (៧)ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និងវិធានការកាត់បន្ថយ (៨)ផែនការគ្រប់គ្រងបរិស្ថាន, (៩) ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន, និង (១០) សន្និដ្ឋាន និងអនុសាសន៍ ។

## ១.២ គោលបំណងនៃការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនេះ

ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍ ប្រទេសជាតិប្រកបដោយនិរន្តរភាពស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល កម្ពុជានោះរាល់គម្រោងអភិវឌ្ឍន៍ទាំងអស់ ត្រូវធ្វើការសិក្សាវាយតម្លៃលើហេតុប៉ះពាល់បរិស្ថានជាមុនសិនរួច នឹងឈានចូលការអនុវត្ត គម្រោង និងយោងតាមច្បាប់កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុ ប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា ការសិក្សាសម្រាប់កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់គម្រោងនេះ គឺមានគោលបំណងសំខាន់ៗដូចតទៅ ៖

- សិក្សាលម្អិត និងស្វែងយល់ពីធនធានបរិស្ថានដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គម្រោង។
- សិក្សាលម្អិតសេដ្ឋកិច្ច-សង្គមនៃតំបន់គម្រោងនឹងអភិវឌ្ឍ និងសិក្សាធ្វើការវិភាគលើតំបន់ជុំវិញតំបន់គម្រោង ដែលអាចទទួលរងនូវឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលពីគម្រោងស្នើសុំអភិវឌ្ឍនេះ រួមទាំងបណ្តុំនៃផលប៉ះពាល់រួមគ្នាជាមួយគម្រោងដទៃទៀត ផងដែរប្រសិនបើមាន។
- កំណត់នូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថានវិជ្ជមាន និងអវិជ្ជមាន ដែលកើតឡើងពីសកម្មភាពរបស់គម្រោងដោយប្រើប្រាស់តារាង Checklist របស់ធានាគារអភិវឌ្ឍន៍អាស៊ី និងរបស់ក្រសួងបរិស្ថានកម្ពុជាដើម្បីជាទិសដៅក្នុងការសិក្សា។
- ដកស្រង់នូវអនុសាសន៍ និងទទួលយកនូវសំណូមពររបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោង និងស្ថាប័នសាធារណៈដែលពាក់ព័ន្ធ នឹងគម្រោងក្នុងនោះក៏មានអង្គការក្រៅរដ្ឋាភិបាលផងដែរ ដើម្បីរិះរកវិធានការយ៉ាងសុក្រឹត សម្រាប់បន្ធូរបន្ថយ ផលប៉ះពាល់ បរិស្ថានអវិជ្ជមានឱ្យដល់តិចបំផុតតាមការដែលអាចធ្វើទៅបាន។
- វាយតម្លៃ និងប៉ាន់ប្រមាណហេតុប៉ះពាល់លើធនធានបរិស្ថានធម្មជាតិ និងសង្គម ដែលបណ្តាលមកពីការរចនាប្លង់ ការសាងសង់ ប្រតិបត្តិថែទាំគម្រោង និងបញ្ចប់ ឬបិទគម្រោង។
- ធ្វើការវិភាគសេដ្ឋកិច្ចនៃតម្លៃស្តារហេតុប៉ះពាល់បរិស្ថានអវិជ្ជមានរបស់គម្រោងដោយបញ្ជាក់ថា តម្លៃស្តារបរិស្ថាននេះគ្រប់គ្រាន់ខាត ឬចំណេញ ក្នុងដំណាក់កាលប្រតិបត្តិគម្រោងថែទាំគម្រោង ជាពិសេស គឺធ្វើឱ្យធនធានព្រៃឈើ និងជលផលបានស្តារឡើងវិញក្នុងរយៈពេលណាមួយកំណត់ ឬមួយក្រុមហ៊ុនត្រូវបង្កើនតម្លៃបរិស្ថាននេះបន្ថែមទៀត។
- ធ្វើការវិភាគសេដ្ឋកិច្ចនៃគម្រោងដោយរួមទាំងការខូចខាតធនធានបរិស្ថានធម្មជាតិ ជីវសាស្ត្រ និងសង្គម ដើម្បីរកផលចំណេញរបស់គម្រោង។
- កំណត់នូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ជាពិសេស លើបរិស្ថានសង្គមឱ្យដល់កម្រិតអប្បបរមា
- កំណត់នូវផែនការការពារបរិស្ថានរបស់គម្រោងទៅថ្ងៃអនាគត។
- ធ្វើការសន្និដ្ឋាន និងផ្តល់អនុសាស្ត្រសំខាន់ៗ ដែលធ្វើឱ្យម្ចាស់គម្រោង និងស្ថាប័នទទួលខុសត្រូវអនុវត្តគម្រោងដោយមានភាពរលូន និងមានភាពនិរន្តភាព។

Draft